

# ព្រះយេស៊ូវគ្រីស្ទបានព្យាបាលបុរសម្នាក់

នៅថ្ងៃមួយ ព្រះយេស៊ូវគ្រីស្ទបានទតឃើញបុរសពិការភ្នែកម្នាក់ ។ មនុស្សខ្លះបានគិតថា ព្រះបានធ្វើឲ្យបុរសនោះពិការភ្នែកដើម្បីជាការដាក់ទោសគាត់ ។ « តើមនុស្សនេះបានធ្វើបាបឬ ? ឬតើឪពុកម្ដាយរបស់គាត់បានធ្វើបាបឬ ? ពួកគេបានសួរ ។

ព្រះយេស៊ូវបានមានបន្ទូលថា ការពិការភ្នែករបស់បុរសនេះមិនមែនជាការដាក់ទោសទេ ។ ទ្រង់បានមានបន្ទូលឆ្លើយថា ៖ « មិនមែនដោយព្រោះអ្នកនេះ ឬឪពុកម្ដាយគាត់បានធ្វើបាបទេ » ។

ព្រះយេស៊ូវបានយកភក់ទៅលាបភ្នែកបុរសនោះ ។ បន្ទាប់មក ទ្រង់បានមានបន្ទូលឲ្យបុរសនោះទៅលាងភ្នែករបស់គាត់នៅក្នុងស្រះ ។ នៅពេលបុរសនោះបានធ្វើតាមអ្វីដែលព្រះយេស៊ូវបានមានបន្ទូល គាត់ក៏បានជា ! បុរសនោះអាចមើលឃើញ ។

ពេលខ្លះ រឿងលំបាកៗអាចកើតឡើងចំពោះយើង ។ ព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាសួគ៌អាចជួយយើងរៀន រីកចម្រើន និងមានភាពសុខសាន្ត ។ ទ្រង់ទាំងទ្វេស្រឡាញ់យើង និងសព្វព្រះទ័យប្រទានពរដល់យើង !

សូមហែកទំព័រនេះចេញ ហើយបត់វាជាពីរ ។ បន្ទាប់មកសូមលើករូបភាពឡើងនៅពេលអ្នកនិទានរឿងនោះ ។




*អ្នកអាចអានដំណើរឿងនេះនៅក្នុង យ៉ូហាន ៩:១–១១ ។*

